**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៤១ សហវ.ប្រក

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែ និងថាមពល

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញបទប្បញ្ញត្តិប្រេងកាតកម្ពុជាលេខ ០១បបញ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩១
- បានឃើញសេចក្តីសម្រេចលេខ ៧៣សសរ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសម្រួលជំពូក២ នៃបទប្បញ្ញត្តិប្រេងកាតកម្ពុជា ឆ្នាំ១៩៩១
- បានឃើញសេចក្តីសម្រេចលេខ ២៥សសរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិប្រេងកាតកម្ពុជា ឆ្នាំ១៩៩១
- បានឃើញប្រកាសលេខ ០០៩២ រថ.បវប.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាលស្តីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលាសិលា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## **សម្រេច**

**ប្រការ ១.-**

អនុញ្ញាតឱ្យក្រសួងរ៉ែ និងថាមពល អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

សេវាសាធារណៈដែលផ្តល់ដោយក្រសួងរ៉ែ និងថាមពល ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ ២.-**

ក្រសួងរ៉ែ និងថាមពល ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវានូវស្តង់ដារសេវា ក្នុងនោះរួមមាន កម្រងសេវាសាធារណៈដែលកំណត់ដោយប្រការ ១ នៃប្រកាសរួមនេះ, ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

ក្រសួងរ៉ែ និងថាមពល ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣.-**

ក្រសួងរ៉ែ និងថាមពល មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវលើប្រាក់ចំណូលដែលប្រមូលបាន និងការបង់ប្រាក់ចំណូលចូលថវិកាជាតិ។ ទន្ទឹមនឹងនោះ ក្រសួងរ៉ែ និងថាមពល ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៤.-**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ រវាងរដ្ឋបាលកណ្តាលក្រសួងរ៉ែ និងថាមពល និងមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។ ក្រសួងរ៉ែ និងថាមពល ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្ត។

**ប្រការ ៥.-**

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដែលមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦.-**

ក្រសួងរ៉ែ និងថាមពល ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧._**

ក្រសួងរ៉ែ និងថាមពល ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨._**

កម្រៃសេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួម។

**ប្រការ ៩._**

និរាករណ៍ទាំងស្រុងប្រកាសរួមលេខ ១០០៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០._**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល_÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត

**«ដើម្បីជូនជ្រាប»**

- ដូចប្រការ ១០ **«ដើម្បីមុខការ»**
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៤៩ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១៥

## ស្តីពីការផ្តល់សេវាសាធារណ: និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែ និងថាមពល

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **I. ការផ្តល់សេវាសាធារណ:** | | | | |
| **I.១- អគ្គនាយកដ្ឋានធនធានរ៉ែ (អាជ្ញាប័ណ្ណធនធានរ៉ែ)** | | | | |
| ក. ការផ្តល់អាជ្ញាប័ណ្ណ | | | | |
| ១ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | ១០០ ០០០ រៀល | ១០ថ្ងៃ | |
| ២ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត | ៥០០ ០០០ រៀល | ១៥ថ្ងៃ | |
| ៣ | លិខិតអនុញ្ញាតបុរេសនា | ៤ ០០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ៤ | ផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | ១០០ ០០០ រៀល | ៤៥ថ្ងៃ | ១ឆ្នាំ |
| ៥ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៦ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្ទងសិលា និងថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ៧ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១ឆ្នាំ |
| ៨ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ១៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៩ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ៣ ៦០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៧ ២០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១១ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ១៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១២ | អាជ្ញាប័ណ្ណស្វែងរុករក | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១៣ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១ឆ្នាំ |
| ១៤ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ | ៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៥ឆ្នាំ |
| ខ. ការចុះបញ្ជីអាជ្ញាប័ណ្ណ | | | | |
| ១៥ | អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | ៥០ ០០០ រៀល | ៣០ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ១៦ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៨០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ១៧ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និង ថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ១ ៥០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ១៨ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ១០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ១៩ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូង ថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ៣ ០០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ២០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ | ៨០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ២១ | អាជ្ញាប័ណ្ណស្វែងរុករក | ៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ២២ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| ២៣ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ | ១៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាប័ណ្ណ |
| គ. ការពន្យារបន្តអាជ្ញាប័ណ្ណ | | | | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៤ | អាជ្ញាប័ណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២៥ | អាជ្ញាប័ណ្ណស្វែងរុករក | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២៦ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែទ្រង់ទ្រាយធំ | ៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៥ឆ្នាំ |
| ឃ. ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ | | | | |
| ២៧ | អាជ្ញាប័ណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ២៨ | អាជ្ញាប័ណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ២៩ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃទ្រង់ទ្រាយធំ | ៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ២ ៥០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣១ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣២ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ៨ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៣៣ | អាជ្ញាប័ណ្ណស្វែងរុករក | ១០០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣៤ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែទ្រង់ទ្រាយធំ | ២០០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ង. ការចេញលិខិតទទួលស្គាល់ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលក្រោម ៥០%) | | | | |
| ៣៥ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ២ ៥០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣៦ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ១៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣៧ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | ២០ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣៨ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ១ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៣៩ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ១ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤០ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ១ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤១ | អាជ្ញាប័ណ្ណស្វែងរុករក | ៤០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤២ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ | ១០០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ច. ការចេញលិខិតទទួលស្គាល់ការផ្លាស់ប្តូរសមាសភាពភាគហ៊ុន ឬ/និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងក្រុមហ៊ុន (ដែលមានការប្រែប្រួលចាប់ពី ៥០% ឡើងទៅ) | | | | |
| ៤៣ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ខ្សាច់សំណង់ ក្រួស ឡាតេរីត ដីឥដ្ឋ | ៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤៤ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ថ្មសំណង់ ថ្មអារ ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ២៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤៥ | អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | ២៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤៦ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មតិចជាង ៧នាក់ | ៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤៧ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មពី ៧នាក់ ទៅ ១៤នាក់ | ៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤៨ | អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមានកម្លាំងពលកម្មលើសពី ១៤នាក់ | ៥ ០០០ ០០០ រៀល | ៣០ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ៤៩ | អាជ្ញាប័ណ្ណស្វែងរុករក | ៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី ក្នុងសុពលភាពអាជ្ញាប័ណ្ណ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៥០ | អាជ្ញាប័ណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ | ១០០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មីក្នុងសុពលភាពអាជ្ញាប័ណ្ណ |
| ឆ. ការចេញលិខិតបញ្ជាក់សំណាករ៉ែ និងធនធានរ៉ែសម្រាប់គោលបំណងនាំចេញ-នាំចូល | | | | |
| ៥១ | លិខិតបញ្ជាក់សំណាករ៉ែ | ៥០០ ០០០ រៀល | ១០ថ្ងៃ | ៣០ថ្ងៃ |
| ៥២ | លិខិតបញ្ជាក់ធនធានរ៉ែ | ១ ០០០ ០០០ រៀល | ១០ថ្ងៃ | ៣០ថ្ងៃ |
| I.២- **អគ្គនាយកដ្ឋានប្រេងកាត** | | | | |
| ក. ផ្នែកអាប់ស្រ្ទីម | | | | |
| ១ | លិខិតអនុញ្ញាតលើការដាក់ពាក្យចូលដេញថ្លៃប្លុកប្រេងកាត ឬការដាក់ពាក្យស្នើសុំប្លុកប្រេងកាត | ៤ ០០០ ដុល្លារ | ៤៥ថ្ងៃ | ៣ខែ |
| ២ | លិខិតអនុញ្ញាតលើការចរចាកិច្ចព្រមព្រៀងប្រេងកាត (PSC) ឬការចរចារកិច្ចព្រមព្រៀងបុរេសនា (Prospective Agreement) | ៥០ ០០០ ដុល្លារ | ១៨០ថ្ងៃ | ១ឆ្នាំ |
| ៣ | លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្ទេរសិទ្ធិគ្រប់គ្រង/ ការប្តូរអំណាចគ្រប់គ្រងគម្រោងប្រេងកាត (Transfer of right/change of control) | ១០០ ០០០ ដុល្លារ | ៩០ថ្ងៃ | រហូតដល់មានលិខិតទទួលស្គាល់ថ្មី |
| ៤ | លិខិតអនុញ្ញាតលើការទទួលស្គាល់ការលក់ភាគហ៊ុន ចេញ ឬចូល (Farm in/Farm out) | ៥០ ០០០ ដុល្លារ | ៩០ថ្ងៃ | រហូតដល់មានលិខិតទទួលស្គាល់ថ្មី |
| ៥ | លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្លាស់ប្តូរប្រតិបត្តិករដែលទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងប្រេងកាត (Change Operator) | ៥ ០០០ ដុល្លារ | ១៥ថ្ងៃ | រហូតដល់មានលិខិតទទួលស្គាល់ថ្មី |
| ៦ | លិខិតអនុញ្ញាតផលិតកម្មប្រេងកាត (Production Permit) | ១០០ ០០០ ដុល្លារ | ១៨០ថ្ងៃ | តាមគម្រោងផលិតកម្ម |
| ៧ | លិខិតអនុញ្ញាតផលិតកម្មដើម្បីអភិវឌ្ឍន៍ទីផ្សារពាណិជ្ជកម្មឧស្ម័ន | ១០ ០០០ ដុល្លារ | ៩០ថ្ងៃ | មិនលើសពី ១០ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៨ | លិខិតអនុញ្ញាតបង្កើត និងដំណើរការមូលដ្ឋានផ្គត់ផ្គង់សម្ភារៈប្រតិបត្តិការប្រេងកាត | ២៥ ០០០ ដុល្លារ | ១៨០ថ្ងៃ | ៥ ឆ្នាំ |
| ៩ | លិខិតពន្យារបន្ត ឬកែសម្រួលរយៈពេលចរចាកិច្ចព្រមព្រៀងប្រេងកាត | ៥ ០០០ ដុល្លារ | ៤៥ថ្ងៃ | មិនលើសពី ៦ខែ |
| ១០ | លិខិតពន្យារបន្ត ឬកែសម្រួលលើលិខិតអនុញ្ញាតចូលដំណាក់កាលទី២ ឬ ដំណាក់កាលទី៣ នៃរយៈពេលស្វែងរុករក | ១០ ០០០ ដុល្លារ | ៣០ថ្ងៃ | ២ ឆ្នាំ |
| ១១ | លិខិតពន្យារបន្ត ឬកែសម្រួលរយៈពេលស្វែងរុករកលើសពីដំណាក់កាលទី៣ នៃរយៈពេលស្វែងរុករក | ១០ ០០០ ដុល្លារ | ៣០ថ្ងៃ | មិនលើសពី ៦ខែ |
| ១២ | លិខិតអនុញ្ញាតកែសម្រួលលើគម្រោងអភិវឌ្ឍប្រេងកាត | ១០ ០០០ ដុល្លារ | ៤៥ថ្ងៃ | រហូតដល់មានលិខិតអនុញ្ញាតកែប្រែ |
| ១៣ | លិខិតពន្យារបន្ត ឬកែសម្រួលលើលិខិតអនុញ្ញាតបន្តផលិតកម្ម (Extension of Production Permit) | ២៥ ០០០ ដុល្លារ | ៩០ថ្ងៃ | រហូតដល់មានលិខិតអនុញ្ញាតកែប្រែ |
| ១៤ | លិខិតពន្យារបន្ត ឬកែសម្រួលលើលិខិតអនុញ្ញាតពន្យារបន្តដំណើរការមូលដ្ឋានផ្គត់ផ្គង់សម្ភារៈប្រតិបត្តិការប្រេងកាត | ១២ ៥០០ ដុល្លារ | ៤៥ថ្ងៃ | ៥ឆ្នាំ |
| ១៥ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត ឯកសារភូគព្ភសាស្ត្រ និងរូបភូគព្ភសាស្ត្រប្រេងកាតកម្ពុជាឆ្នាំ១៩៨៩ | ២ ០០០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |
| ១៦ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត ឯកសារវាស់ស្ទង់ ប្រព្រឹត្តកម្ម និងបកប្រែ Airborne Gravity and Magnetic ឆ្នាំ១៩៩៨ | ៥ ០០០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៧ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារសិក្សាស្រាវជ្រាវអតីតប្លុក I និង II ដែនសមុទ្រ ដែលធ្វើឡើងមុនឆ្នាំ ១៩៩៨ | ៦ ០០០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |
| ១៨ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារសិក្សាស្រាវជ្រាវអតីតប្លុក III ដែនសមុទ្រ ដែលធ្វើឡើងមុនឆ្នាំ១៩៩៨ | ៤ ០០០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |
| ១៩ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារសិក្សាស្រាវជ្រាវអតីតប្លុក IV ដែនសមុទ្រ ដែលធ្វើឡើងមុនឆ្នាំ ១៩៩៨ | ៤ ០០០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |
| ២០ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត កញ្ចប់ឯកសារ Final Technical Report on Regional Study of Block I, II, III, IV, និង VII ដែនសមុទ្រកម្ពុជា ដែលបានធ្វើនៅ ឆ្នាំ ១៩៩៩ | ៥ ០០០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |
| ២១ | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាត ទិន្នន័យរូបភូគព្ភសាស្ត្រ ( PDF File) ដែនគោក ឬ ដែនសមុទ្រ ដែលធ្វើឡើងនៅឆ្នាំ ២០០៨ និង ២០០៩ | ១ ២៥០ ដុល្លារ | ៧ថ្ងៃ | ៨ម៉ោង |
| ២២ | លក់ទិន្នន័យប្រេងកាត ឯកសារវាស់ស្ទង់ ប្រព្រឹត្តកម្ម និងបកប្រែ Airborne Gravity and Magnetic ដែលធ្វើឡើងមុនឆ្នាំ ១៩៩៨ ក្នុងមួយកញ្ចប់ | ១០ ០០០ ដុល្លារ ដល់ ១០០ ០០០ ដុល្លារ | ៧ថ្ងៃ | មិនកំណត់ |
| ២៣ | លក់ទិន្នន័យប្រេងកាត ទិន្នន័យរូបភូគព្ភសាស្ត្រដែនគោកដែលធ្វើឡើងនៅឆ្នាំ ២០០៨ និង ២០០៩ ឬ ដែនសមុទ្រមុនឆ្នាំ២០០២ ក្នុងមួយប្លុក | ១០០ ០០០ ដុល្លារ ដល់ ១ ០០០ ០០០ ដុល្លារ | ៧ថ្ងៃ | មិនកំណត់ |
| ២៤ | ប្រាក់រង្វាន់ចុះហត្ថលេខាកិច្ចព្រមព្រៀងប្រេងកាត (Agreement Signature Bonus) | តាមការព្រមព្រៀង | | |
| ២៥ | ប្រាក់រង្វាន់នៃការរកឃើញប្រេងកាត ដែលមានលក្ខណៈពាណិជ្ជកម្ម (Commercial Discovery Bonus) | តាមការព្រមព្រៀង | | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៦ | ប្រាក់រង្វាន់ផលិតកម្មប្រេងកាត (Production Bonus) | តាមការព្រមព្រៀង | | |
| ២៧ | សេវាកម្មមន្ត្រីចូលរួមក្នុងប្រតិបត្តិការប្រេងកាត( គិតសម្រាប់មន្ត្រី ១ រូបក្នុង ១ ថ្ងៃ) | ១០០ ដុល្លារ | ៧ ថ្ងៃ | តាមកម្មវិធីការងារ |
| ២៨ | លិខិតអនុញ្ញាតសម្រាប់បែបបទនាំចេញ-នាំចូលសំណាករ៉ែប្រេងកាត | ៣៧៥ ដុល្លារ | ១៥ថ្ងៃ | ៣០ថ្ងៃ |
| ២៩ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកក្នុងដំណាក់កាលទី១/១គីឡូម៉ែត្រការ៉េ | ១៥ ដុល្លារ | | ១ឆ្នាំ |
| ៣០ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកក្នុងដំណាក់កាលទី២/១គីឡូម៉ែត្រការ៉េ | ៣០ ដុល្លារ | | ១ឆ្នាំ |
| ៣១ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកក្នុងដំណាក់កាលទី៣/១គីឡូម៉ែត្រការ៉េ | ៤៥ ដុល្លារ | | ១ឆ្នាំ |
| ៣២ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីស្វែងរុករកលើសពីដំណាក់កាលទី៣/១គីឡូម៉ែត្រការ៉េ | ៦០ ដុល្លារ | | ១ឆ្នាំ |
| ៣៣ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីសម្រាប់ការរក្សាទុកតំបន់មានឧស្ម័ន/១គីឡូម៉ែត្រការ៉េ | ១០០ ដុល្លារ | | ១ឆ្នាំ |
| ៣៤ | ឈ្នួលផ្ទៃក្រឡាប្រចាំឆ្នាំលើផ្ទៃដីសម្រាប់ផលិតកម្មប្រេងកាត/១គីឡូម៉ែត្រការ៉េ | ៥០០ ដុល្លារ | | ១ឆ្នាំ |
| ខ. ផ្នែកដោនស្ទ្រីម | | | | |
| ៣៥ | លិខិតអនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពសាងសង់រោងចក្រប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១៨ខែ |
| ៣៦ | លិខិតអនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពសាងសង់បំពង់បង្ហូរប្រេង ឬ ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១៨ខែ |
| ៣៧ | លិខិតអនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពបង្កើតទីតាំងស្តុកទុក ឬលាយ ប្រេង ឬ ឧស្ម័នសម្រាប់ចែកចាយ | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១៨ខែ |
| ៣៨ | ផ្ដល់អាជ្ញាប័ណ្ណប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត (សាងសង់ និងដំណើរការ) | ៤០០ ០០០ ០០០ រៀល | ១៨០ថ្ងៃ | ១០ឆ្នាំ |
| ៣៩ | ផ្ដល់អាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័ន (បំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៣០០ ០០០ ០០០ រៀល | ១៨០ថ្ងៃ | ១០ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤០ | ផ្តល់អាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៨០ ០០០ ០០០ រៀល | ៩០ថ្ងៃ | ១០ឆ្នាំ |
| ៤១ | ផ្តល់អាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៩០ថ្ងៃ | ១០ឆ្នាំ |
| ៤២ | ផ្តល់អាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី ១លានលីត្រចុះ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២ ០០០ ០០០ រៀល | ៩០ថ្ងៃ | ១០ឆ្នាំ |
| ៤៣ | ផ្តល់អាជ្ញាប័ណ្ណពាណិជ្ជកម្មប្រេង ឬ ឧស្ម័ន (នាំចេញ ឬ នាំចូលប្រេង ឬឧស្ម័ន) | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៤៤ | ផ្តល់អាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័នឥន្ធនៈ (ក្រៅពីបំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៤៥ | ការបន្តសុពលភាពអាជ្ញាប័ណ្ណប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត (សាងសង់ និងដំណើរការ) | ២០០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ៤៦ | ការបន្តសុពលភាពអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័ន (បំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ១៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ៤៧ | ការបន្តសុពលភាពអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៨០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ៤៨ | ការបន្តសុពលភាពអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១លានលីត្រ ដល់១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ៤៩ | ការបន្តសុពលភាពអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី១លានលីត្រចុះ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ៥០ | ការបន្តសុពលភាពអាជ្ញាប័ណ្ណពាណិជ្ជកម្មប្រេង ឬ ឧស្ម័ន (នាំចេញ ឬ នាំចូលប្រេង ឬឧស្ម័ន) | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៥១ | ការបន្តសុពលភាពអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័នឥន្ធនៈ (ក្រៅពីបំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ២ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៥២ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត (សាងសង់ និងដំណើរការ) | ២០០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៣ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័ន (បំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ១៥០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៤ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ៤០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៥ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះលើសពី១លានលីត្រដល់ ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ១០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៦ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះក្រោម ១លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៧ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណពាណិជ្ជកម្មប្រេង ឬ ឧស្ម័ន (នាំចេញ ឬ នាំចូលប្រេង ឬឧស្ម័ន) | ៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៨ | ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណដឹកជញ្ជូនប្រេង ឬ ឧស្ម័នឥន្ធនៈ (ក្រៅពីបំពង់បង្ហូរប្រេង ឬ ឧស្ម័ន) | ៥ ០០០ ០០០ រៀល | ៤៥ថ្ងៃ | រហូតមានការផ្ទេរសិទ្ធិថ្មី |
| ៥៩ | លិខិតអនុញ្ញាតសម្រាប់បែបបទនាំចូល ឬ នាំចេញប្រេង ឬ ឧស្ម័ន | ២ ០០០ ០០០ រៀល | ១៥ថ្ងៃ | ៩០ថ្ងៃ |
| ៦០ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត | ៣០ ០០០ ០០០ រៀល | ៩០ថ្ងៃ | ៣ឆ្នាំ |
| ៦១ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការបំពង់បង្ហូរប្រេង ឬ ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៩០ថ្ងៃ | ៣ឆ្នាំ |
| ៦២ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះ លើសពី ១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៩០ថ្ងៃ | ៣ឆ្នាំ |
| ៦៣ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី១លាន លីត្រដល់១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៩០ថ្ងៃ | ៣ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៦៤ | វិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះក្រោម ១លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២ ០០០ ០០០ រៀល | ៩០ថ្ងៃ | ៣ឆ្នាំ |
| ៦៥ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រប្រព្រឹត្តកម្មប្រេងកាត ឬ គីមីប្រេងកាត | ៣០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ៦៦ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការបំពង់បង្ហូរប្រេង ឬ ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ៦៧ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះ លើសពី១០លានលីត្រឡើង ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ៦៨ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះចាប់ពី១លានលីត្រដល់១០លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២០ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ៦៩ | កម្រៃការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការទីតាំងស្តុកទុកប្រេង ឬ ឧស្ម័ន ដែលមានចំណុះក្រោម ១លានលីត្រ ឬ ចំណុះប្រហាក់ប្រហែលសម្រាប់ឧស្ម័ន | ២ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ៧០ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃបង្កើតស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ រៀល | ៤០ថ្ងៃ | មិនកំណត់ |
| ៧១ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ រៀល | ៤០ថ្ងៃ | ២ឆ្នាំ |
| ៧២ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើការបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ រៀល | ៤០ថ្ងៃ | ២ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៧៣ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើលិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ រៀល | ៤០ថ្ងៃ | មិនកំណត់ |
| ៧៤ | ការអនុញ្ញាតផ្សេងៗពាក់ព័ន្ធនឹងស្ថានីយប្រេង ឬ ឧស្ម័នឥន្ធនៈលើលិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ | ១ ១០០ ០០០ រៀល | ១០ថ្ងៃ | មិនកំណត់ |
| I.៣- **អគ្គនាយកដ្ឋានថាមពល** | | | | |
| ក. ការអនុញ្ញាតវិនិយោគសម្រាប់ផលិតកម្មអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន) | | | | |
| ១ | ចេញប្រកាស ឬចេញលិខិតអនុញ្ញាតសម្រាប់ផលិតកម្មអគ្គិសនីដោយប្រើប្រេងម៉ាស៊ូត (DO) ប្រេងខ្មៅ (HFO) វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាពទាបជាង ១ ០០០ គីឡូវ៉ាត់ (P<១ ០០០ kW) | ១០ ០០០ រៀល /គីឡូវ៉ាត់ | ៣០ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| ២ | ចេញប្រកាសអនុញ្ញាត ឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងឱ្យវិនិយោគស្ថានីយអគ្គិសនីដោយប្រើប្រេងម៉ាស៊ូត (DO) ប្រេងខ្មៅ (HFO) ធ្យូងថ្ម វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាពចាប់ពី ១ ០០០ គីឡូវ៉ាត់ ឡើងទៅ (P≥១ ០០០ kW) | ១ ០០០ រៀល /គីឡូវ៉ាត់ | - ៦០ថ្ងៃ សម្រេចត្រឹមក្រសួង<br>- ២០ថ្ងៃ ក្រោយពីទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល | រហូតដល់មានការអនុញ្ញាត ឬចុះកិច្ចព្រមព្រៀងថ្មី |
| ខ. ការអនុញ្ញាតវិនិយោគសម្រាប់បណ្ដាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន) | | | | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៣ | ចេញប្រកាសអនុញ្ញាត ឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគអគ្គិសនីសម្រាប់បណ្តាញអគ្គិសនី តង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ឬ ២៣០ គីឡូវ៉ុល | ១ ០០០ ០០០ /គីឡូម៉ែត្រ | - ៦០ថ្ងៃ សម្រេចត្រឹមក្រសួង - ២០ថ្ងៃ ក្រោយពីទទួលសិទ្ធិប្រទាន | រហូតដល់មានការអនុញ្ញាត ឬចុះកិច្ចព្រមព្រៀងថ្មី |
| ៤ | ចេញប្រកាសអនុញ្ញាតវិនិយោគអគ្គិសនីសម្រាប់បណ្តាញអគ្គិសនីតង់ស្យុងមធ្យម ២២ គីឡូវ៉ុល ឬ ៣៥ គីឡូវ៉ុល | ១០០ ០០០ រៀល /គីឡូម៉ែត្រ | ៤៥ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| ៥ | ចេញប្រកាស ឬចេញលិខិតអនុញ្ញាតវិនិយោគអគ្គិសនីសម្រាប់បណ្តាញអគ្គិសនីតង់ស្យុងទាប ០.៤ គីឡូវ៉ុល ឬ ៣៨០វ៉ុល | ៥០ ០០០ រៀល /គីឡូម៉ែត្រ | ៣០ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| គ. ការអនុញ្ញាតផ្ទេរសិទ្ធិវិនិយោគសម្រាប់ផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន) | | | | |
| ៦ | ចេញប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគផលិតកម្មថាមពលអគ្គិសនី | ១ ០០០ រៀល /គីឡូវ៉ាត់ | ២០ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| ៧ | ចេញប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី | ២០ ០០០ រៀល /គីឡូម៉ែត្រ | ២០ ថ្ងៃ | រហូតដល់មានការអនុញ្ញាតថ្មី |
| ឃ. ការអនុញ្ញាតឱ្យសិក្សា និងពន្យារពេលសិក្សាគម្រោងផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់តែការវិនិយោគឯកជន) | | | | |
| ៨ | ចេញលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនី ដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត | ១ ០០០ រៀល /គីឡូវ៉ាត់ | ៤៥ ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៩ | ចេញលិខិតពន្យារពេលលើលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនីដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត | ១ ០០០ រៀល /គីឡូវ៉ាត់ | ២០ ថ្ងៃ | ០៦ខែ, ១២ខែ ១៨ខែ, ២៤ខែ (អាស្រ័យទំហំវិនិយោគ) |
| ១០ | ចេញលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី | ២០ ០០០ រៀល /គីឡូម៉ែត្រ | ២០ ថ្ងៃ | |
| ១១ | ចេញលិខិតពន្យារពេលលើលិខិតអនុញ្ញាត ឬអនុស្សារណៈយោគយល់គ្នា (MOU) ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី | ២០ ០០០ រៀល /គីឡូម៉ែត្រ | ២០ ថ្ងៃ | |
| II. **ការពិន័យអន្តរការណ៍ជាប្រាក់** | | | | |
| ១ | ករណីផុតសុពលភាពអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម | ១ ០០០ ០០០ រៀល/ថ្ងៃ | | |
| ២ | ករណីផុតសុពលភាពអាជ្ញាប័ណ្ណស្វែងរុករក | ៥០០ ០០០ រៀល/ថ្ងៃ | | |
| ៣ | ករណីផុតសុពលភាពអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ | ៥ ០០០ ០០០ រៀល/ថ្ងៃ | | |
| ៤ | ករណីបង់សួយសារធនធានរ៉ែមិនទាន់កាលកំណត់ | ២%នៃកម្រៃសួយសារ/ខែ | | |
| ៥ | ករណីដំណើរការដោយអាជ្ញាប័ណ្ណធនធានរ៉ែ ផុតសុពលភាព | | | |
| | - អាជ្ញាប័ណ្ណសិប្បកម្ម | ៥០ ០០០/ថ្ងៃ | | |
| | - អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម | ៥០០ ០០០/ថ្ងៃ | | |
| | - អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | ៥០០ ០០០/ថ្ងៃ | | |
| | - អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ | ៥០ ០០០/ថ្ងៃ | | |